Khmer

# នាំគ្នាកាត់បន្ថយ ផលខូចខាត នៃការលេងល្បែងស៊ីសង



Fairfield City
Celebrating diversity

Version Published May 2023



# សារពីអភិបាលក្រុង FRANK CARBONE

## ផលខូចខាតនៃការលេងល្បែងស៊ីសង

ចំពោះអ្នកខ្លះ ការលេងល្បែងស៊ីសងគឺជាទម្រង់មួយនៃការកំសាន្ត ដែលគេលេងយូរៗម្តង ប៉ុន្តែចំពោះអ្នកឯទៀតវិញ វាអាចក្លាយយ៉ាងលឿនទៅជាអ្វីមួយដែលរឹតតែប្រាកដប្រជាថែមទៀត។ នៅក្នុងករណីនោះ អ្នកឬអ្នកណាមួយដែលអ្នកស្គាល់ អាចមានគ្រោះថ្នាក់ទទួលផលខូចខាតពាក់ព័ន្ធនឹងការលេងល្បែងស៊ីសង។ បើការលេងល្បែងស៊ីសងលែងជាការកំសាន្តតទៅទៀតហើយនោះ ជំនួយមានជាស្រេចដោយគ្រាន់តែទាក់ទងតាមរយៈទូរស័ព្ទប៉ុណ្ណោះ។ ការលេងល្បែងស៊ីសងផ្តល់ផលខូចខាតដល់បណ្តាជនច្រើនជាងចំនួនដែលអ្នកប្រហែលជាគិតឃើញទៅទៀត។ ឧទាហរណ៍ វាអាចមានផលប៉ះពាល់ដល់៖

- បញ្ហាប្រាក់កាស
- ជីវិតគ្រួសារ ចំណងមេត្រីភាព និងសហគមន៍
- ការងារនិងការសិក្សា
- សុខភាពរាងកាយនិងផ្លូវចិត្ត

វាជាការសំខាន់ដែលយើងមានសហគមន៍ដ៏រីករាយ មានសុវត្ថិភាព និងរីកលូតលាស់។ ខ្ញុំចង់ឲ្យអ្នកដឹងថា ការស្វែងរកជំនួយមិនមែនជាការអាម៉ាស់ទេ ទោះជាជំហានដំបូងមានភាពលំបាកក៏ដោយ។



សេវាកម្មក្នុងតំបន់ត្រៀមខ្លួនជាស្រេចដើម្បីស្តាប់ យកចិត្តទុកដាក់ ហើយផ្តល់ដំបូន្មាននិងព័ត៌មានដើម្បីជួយអ្នក ទោះជាអ្នកកំពុងស្វែងរកជំនួយសម្រាប់ការលេងល្បែងស៊ីសងរបស់អ្នកផ្ទាល់ ឬបើការលេងល្បែងស៊ីសងរបស់អ្នកណាម្នាក់ផ្សេងទៀតកំពុងបណ្តាលឲ្យមានសេចក្តីបារម្ភក៏ដោយ។

សាលាក្រុងត្រៀមខ្លួនជាស្រេចជានិច្ចសម្រាប់សហគមន៍។ យើងធ្វើការជិតស្និទ្ធជាមួយសេវាកម្មដែលមានចំណេះដឹងនិងបទពិសោធន៍ដើម្បីផ្តល់ជំនួយ។

បើអ្នក ឬជនណាម្នាក់ដែលអ្នកស្គាល់កំពុងជួបប្រទះនឹងផលខូចខាតពាក់ព័ន្ធនឹងការលេងល្បែងស៊ីសង អ្នកអាចទាក់ទង GambleAware តាមលេខ 1800 858 858 ឬបើកមើលវិបសៃ www.gambleaware.nsw.gov.au ដើម្បីស្វែងដឹង

- គន្លឹះសំខាន់អំពីការគ្រប់គ្រងការលេងល្បែងស៊ីសង
- វិធីជួយខ្លួនឯងនិងអ្នកដទៃ
- ព័ត៌មានជាភាសាផ្សេងទៀត





## វិធីផ្សេងទៀតដើម្បីជួយ

- Gamblers Anonymous (Oakdene House)
  (02) 9727 5519
- ពិភាក្សាជាមួយវេជ្ជបណ្ឌិតឬអ្នកពិគ្រោះយោបល់

ស្កេនកូដ QR ដើម្បីទទួលព័ត៌មានបន្ថែមអំពីផលខូចខាតនៃការលេងល្បែងស៊ីសង

## តើអ្នកបានដឹងទេ?

ចំនួនប្រាក់ 1.8 លានដុល្លារក្នុងមួយថ្ងៃត្រូវបានចាញ់ដោយសារការលេងម៉ាស៊ីនចុចកាក់នៅតាមទីកន្លែងទាំងឡាយនៃក្រុង Fairfield

ម៉ាស៊ីនចុចកាក់នៅក្រុង Fairfield មានច្រើនជាងម៉ាស៊ីនចុចកាក់ទាំងអស់នៅក្នុងរដ្ឋ Tasmania

គ្រាន់តែក្រុមហ៊ុនលេងល្បែងស៊ីសងតាមអនឡាញមានចំនួនជាង 50 នៅក្នុងប្រទេសអូស្ត្រាលី